# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ៖ ០៣១/០៧ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ កញ្ញា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កញ្ញា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាព គ្រប់គ្រងគម្រោង ជា អង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបាន កំណត់ ក្នុងស្មារតីទទួល ខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

ក. ***<u>ការងាររដ្ឋបាល</u>***

-ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការរៀបចំ និងការអនុវត្តគម្រោងតុលាការគំរូ នៅកម្ពុជា នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៧

-ផ្ញើតារាងភាពជឿនលឿននៃការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ឆមាសទី១ ឆ្នាំ២០០៧ ក្នុង ក្របខ័ណ្ឌ GAP II ទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

ខ. ***<u>ការងារកំណែទម្រង់</u>***

-រៀបចំកិច្ចប្រជុំស្តីពីការរៀបចំ និងអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៧ នៅអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងតាមដាន កំណែទម្រង់ ច្បាប់ និងតុលាការ

-

រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និង តុលាការ នៅខេត្តពោធិ៍សាត់ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៧

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែ-ទម្រង់ច្បាប់ និង តុលាការ នៅខេត្តពោធិ៍សាត់ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៧ និងនៅខេត្តកំពង់ចាម នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៧

-ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទី ២ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧

-ប្រជុំអង្គភាពគ្រប់គ្រងគម្រោងអំពីយុទ្ធសាស្រ្តក្នុងការទំនាក់ទំនង(Communication Strategy) នៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៧

-ជួបពិភាក្សាជាមួយក្រុមការងាររៀបចំ Database នៅកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)

-ជួបពិភាក្សាជាមួយក្រុមការងាររៀបចំ ស្តីពីការរៀបចំប្រព័ន្ធសូចនាករកំណែទម្រង់ច្បាប់ និង តុលាការ។

គ. <u>ផ្សេងៗ</u>

-ចូលរួមប្រជុំក្រុមការងារពង្រឹងសាលាភូមិន្ទរដ្ឋបាល នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០០៧

-ពិនិត្យកែលំអសេចក្តីព្រាងនីតិវិធីតាក់តែងច្បាប់ និងចូលរួមប្រជុំក្រុមការងារនីតិវិធី-តាក់តែងច្បាប់ នៅ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧។

**២-សន្និដ្ឋាន**

ក្នុងខែ កញ្ញា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្រ្តៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជា អង្គភាពប្រតិបត្តិ បានបន្តកិច្ចការពាក់ព័ន្ធ នឹងការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ ច្បាប់ និងតុលាការ ទៅតាមអាទិភាពដែលបានកំណត់ ដោយផ្តោតជាសំខាន់ទៅលើការរៀបចំការអនុវត្តគម្រោង ស្តីពីការពង្រីកបន្ថែមតុលាការគំរូ និងការរៀបចំ ប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ និងធ្វើសេចក្តីសម្រេចបង្កើត ក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងតាមដានកំណែទម្រង់ច្បាប់ និងតុលាការ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-រៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់តុលាការគំរូ

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ ច្បាប់ និង តុលាការ នៅខេត្តមណ្ឌលគីរី

-បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោងតាមរយៈការប្រជុំពិភាក្សាតាមអនុក្រុម (Sub-Group/TWG)

-ផ្ញើលិខិតទៅតាមក្រសួងស្ថាប័នពាក់ព័ន្ធ សុំចាត់តាំងតំណាងចូលរួមជាសមាជិកនៃក្រុមការងារ បច្ចេកទេសប្រព័ន្ធសូចនាករ និងតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-ទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំសេចក្តីព្រាងសៀវភៅវិស័យ- យុត្តិធម៌

-ពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស (DIHR) អំពីកិច្ចសហការរវាងអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង និងវិទ្យាស្ថានដាណឺម៉ាកដើម្បីសិទ្ធិមនុស្ស សម្រាប់ឆ្នាំ២០០៨

-ពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស អំពីគម្រោងប្រព័ន្ធសូចនាករ។

*រាជធានី ភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ិុយ ម៉ុងលាង